មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការរុករក និង ជួយសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ ។

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនក្រុមហ៊ុនកាំម៉ិច (CAMEPEX) ដែលមានទឹកចិត្តមនុស្សធម៌ បានបញ្ជូនឧទ្ធម្ភាគចក្រមួយគ្រឿងផុន PUMA-330J ទៅជួយសង្គ្រោះជនរងគ្រោះចំនួន ១៥រូប ក្នុងឧប្បត្តិហេតុធ្លាក់យន្តហោះនៅតំបន់ភ្នំជី ខេត្តកំពង់ធំនាខែសីហា ឆ្នាំ១៩៩៦ កន្លងមក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងគណៈកម្មការសំរាប់រុករក និងជួយសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០១ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមសលំដាប់ថ្នាក់ជូនសប្បុរសជន ដែលមាន សទ្ធាជ្រះថ្លាបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលសាធារណៈនានា នៅក្នុងស្រុកបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ ÷

ក_ មេដាយមាស ស្ថាបនាជាតិ

១_ពុទ្ធបរិស័ទចណុះជើងវត្ត និគមរាម	ទឹកប្រាក់ 13.563 USD
២_លោក ចៅ វ៉ាន់សាន់ នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ 12.000 USD
៣_លោក ស៊ិន សៀន នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ 12.515 USD

ខ_ មេដាយប្រាក់ ស្ថាបនាជាតិ

១_អ្នកស្រី អិន ម៉េង នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 6.000 USD

គ_ មេដាយសំរិទ្ធ ស្ថាបនាជាតិ

១_ក្រុមជំនុំគ្រិស្តបរិសុទ្ធដំណឹងល្អខ្មែរ ភូមិចោយយ៉ង់ ឃុំតាពូង ស្រុកបាត់ដំបង ទឹកប្រាក់ 2.200 USD

២_លោក ញ៉ាវ យ៉ង់ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 3.000 USD

៣_លោក សែម គង់ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 2.000 USD

៤_លោក ផេង ហៀក នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 2.000 USD

៥_លោក អ៊ុម សុងអ៊ីម នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 1.900 USD

៦_លោក ហាប ហ៊ឹ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 1.000 USD

៧_លោក គង់ ញ៉ាញ់ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 1.000 USD

៨_លោក ពៅ រិន នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 1.000 USD

៩_លោក ទូច ប៊ុនថន នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 1.000 USD

១០_លោក ព្រាប ឌុយណេ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ 1.000 USD

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០២ អនក្រ/គត
ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសរបស់ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរតនគិរី

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយប្រាក់ស្ថាបនាជាតិ ជូនលោក ជ័ សេដ្ឋា ដែលបានបរិច្ចាគទឹកប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក សំរាប់ចូលរួមជួយកសាងអាគារសិក្សា នៅសាលាបឋមសិក្សា យក្សឡោម ក្នុងខេត្តរតនគិរី ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

អនុក្រឹត្យលេខ ១០៣ អនក្រ/បក

ស្តីពី ការជូនមេដាយមាសស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៤/៧២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការបង្គ្រប់និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ចំនួន ០២គ្រឿង ជូនអង្គការ JHP ជប៉ុន ដែលបានចំណាយថវិកាជួយកសាងអាគារសិក្សា ២កន្លែង នៅក្រុងព្រះសីហនុ ដូចមានឈ្មោះដូចខាងក្រោម ÷

១_អាគារសិក្សា ៣ខ្នង នៅសាលាបឋមសិក្សាទំនប់រលកចាស់ អស់ទឹកប្រាក់ ៧៧.៣០០$ US

២_អាគារសិក្សា ០១ខ្នង នៅសាលាបឋមសិក្សាទួលទទឹង ស្រុកព្រៃនប់ អស់ទឹកប្រាក់ ២៤.៣៥០$ US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០៤ អនក្រ/តត
ស្តីពី ការជូនមេដាយស្ហាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកកសាងប្រទេសជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈសម្តេចនាយករដ្ឋមន្ត្រីទី២ ដោយបានកសាងអាគារសិក្សា ២ខ្នង ផ្លូវលំប្រវែង ១៧គីឡូម៉ែត្រនិងស្ពានប្រវែង ៣៥ម៉ែត្រ នៅក្នុងស្រុកកងមាស ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់សរុបចំនួន ២៦០.០០០ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ÷

១_លោក **ស៊ុំ សិរះ** ប្រធានក្រុមហ៊ុនអូឡាំពិកភ្នំពេញ

២_លោក **ហេង ឈាន់ម៉ឹង** អគ្គនាយកសម្ព័ន្ធយានកាយ តៃវ៉ាន់

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០៥ អនក្រ/តត

ស្តីពី ការផ្តល់មេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្សទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេច ជា ស៊ីម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគផ្ទាល់ខ្លួនសំរាប់ការកសាងសាលារៀនមួយខ្នងនៅស្រុកឈូក ខេត្តកំពត ដូចមានរាយនាមខាងក្រោម ÷

១_លោក **ថោង ស៊ុត** បរិច្ចាគទឹកប្រាក់ ១៤.២៥០ ដុល្លារអាមេរិក

២_លោក **ឃី គុយ** បរិច្ចាគទឹកប្រាក់ ១៤.២៥០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងនាយកខុទ្ទកាល័យសម្តេច **ជា ស៊ីម** ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០៦ អនក្រ/បក

ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ សិរីស្ថាបនាជាតិ ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសាលាបឋមសិក្សា ប្រាសាទនាងខ្មៅ ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយនាមក្រោមនេះ ÷

១_លោកយាយ **ឧត្តមា ពេជ្ររួន** និងបុត្រធីតា បរិច្ចាគទឹកប្រាក់ ៣.០០០ដុល្លារ អាមេរិក

២_លោក **ទិត្យ សារ៉ុម** និងអ្នកស្រី **អ៊ឹម ហ៊ាង** បរិច្ចាគទឹកប្រាក់ ២.៥០០ដុល្លារ អាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តនូវ ... នេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ...

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០៧ អនក្រ/តត

ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

សំរេច

មាត្រា ១ ផ្តល់ប្រគល់មេដាយមាសស្ថាបនាជាតិ ជូនដល់ពុទ្ធសាសនិកជប៉ុនចំនួន ០៩រូប ដែលបានបរិច្ចាគទឹកប្រាក់ចំនួន ២០លានយ៉េន (១៦០.០០០$ US) ថ្វាយព្រះមហាក្សត្រកម្ពុជា និងជូនក្រសួងធម្មការនិងសាសនា សំរាប់ទ្រទ្រង់ដល់ការងារពុទ្ធសាសនានៅកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ ÷

១_ Most. Ven. Kyuse Enshinjoh

២- Madame Akiyo Fukui

៣- Most. Ven. Shinkai kori

៤- Madame Chie Kori

៥- Venerable shinku Miyagawa

៦- Venerable Hiroshi Fujikura

៧- Vinerable Fukui Shin Sho

៨- Venerable komatsu Takanori

៩- Venerable Ut Sunomiya Masayoshi

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០៨ អនក្រ/បក

ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជនជប៉ុន ០៥រូប ដែលបានឧបត្ថម្ភថវិកា សំរាប់កសាងសាលាបាលីរងមួយខ្នង នៅខេត្តកំពង់ចាម និងបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យមួយខ្នង នៅក្រុងព្រះសីហនុ ដូចមានឈ្មោះដូចខាងក្រោមនេះ ÷

ក_មេដាយ មាស ស្ថាបនាជាតិ

1-Rev Muchaku Seikyo and Muchaku Toki ទឹកប្រាក់ 12.142 $US

2-SVA Chiba ទឹកប្រាក់ 10.000 $US

ខ_មេដាយ ប្រាក់ ស្ថាបនាជាតិ :

1-Rev Kono Taitsu ទឹកប្រាក់ 6.375$US

គ_មេដាយ សំរិទ្ធ ស្ថាបនាជាតិ

1-Mr. Kasahare Hisao ទឹកប្រាក់ 4.350$US

2-Rev. Sato Shodo	ទឹកប្រាក់ 3.636$US
3-Rev. Uchino Kyu	ទឹកប្រាក់ 2.727$US
4-Rev. Sunakochi Ryukan	ទឹកប្រាក់ 2 727$US
5-Rev. Ryoko tonono Kai	ទឹកប្រាក់ 2 727$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១០៩ អនក្រ/គត

ស្តីពី ការជូនមេដាយស្ហាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងអាគារសិក្សា នៅវិទ្យាល័យសិរីមង្គល និងផ្លូវលំ ព្រមទាំងទំនប់ នៅក្នុងឃុំរការកោង និងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ ៖

ក_មេដាយ មាស ស្ថាបនាជាតិ :

១_ឯកឧត្តម **តាច សេខហួរ** និង លោកជំទាវ

ខ_មេដាយ ប្រាក់ ស្ថាបនាជាតិ :

១_លោក និងលោកស្រី **ឡុង ប៊ុននី**

២_លោក និង លោកស្រី **អ៊ំ សារិត**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

អនុក្រឹត្យលេខ ១១០ អនក្រ/តត

ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិ ជូនសប្បុរសជនចំនួន ៨៦នាក់ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមស្តារ និងកសាងប្រទេសជាតិ តាមរយៈសម្តេចនាយករដ្ឋមន្ត្រីទី២ ដូចមានរាយនាមខាងក្រោមនេះ ÷

១_ឯកឧត្តម **គន់ គីម** ទឹកប្រាក់ 66.000$US កសាងសាលារៀន ៣ខ្នង នៅស្រុកកំពង់រោទិ៍

២_ឯកឧត្តម **ហុក ឡង់ឌី** ទឹកប្រាក់ 66.000$US កសាងសាលារៀន ៣ខ្នង នៅស្រុកកំពង់រោទិ៍

៣_ឯកឧត្តម **ទៃ គីមយ៉ាន** ទឹកប្រាក់ 130.000$US កសាងសាលារៀន នៅខេត្តបន្ទាយមានជ័យ

៤_លោកឧកញ៉ា **ភុក សាន** ទឹកប្រាក់ 44.000$US កសាងសាលារៀន ១ខ្នង នៅខេត្តព្រៃវែង និង ១០.០០០$ ទៀត ជួយប្រជាជនក្រីក្រ

៥_លោកឧកញ៉ា **គង់ ទ្រីម** ទឹកប្រាក់ 40.000$US កសាងសាលារៀន ២ខ្នង នៅស្រុកស៊ឹងត្រង់

៦_លោកឧកញ៉ា **សុខ គង់** ទឹកប្រាក់ 125.000$US ជួយប្រជាជនរងគ្រោះដោយទឹកជំនន់

៧_លោកឧកញ៉ា **អ៊ុំ ម៉ិនហ៊ួច** ទឹកប្រាក់ 50.000$US កសាងសាលារៀន ២ខ្នង នៅខេត្តកណ្តាល

៨_ឯកឧត្ដម **គៀង សាវុធ** ទឹកប្រាក់ 10.000$US ជួយប្រជាជនរងគ្រោះដោយទឹកជំនន់

៩_លោកឧកញ៉ា **ចៅ ឬទ្ធី** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកត្បូងឃ្មុំ

១០_លោកឧកញ៉ា **ឈរា ម៉ារឌី** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកត្បូងឃ្មុំ

១១_លោកឧកញ៉ា **ស៊ឹម វណ្ណា** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកស្ទឹងត្រង់

១២_លោកឧកញ៉ា **ហេង សារិត** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកកងមាស

១៣_លោកឧកញ៉ា **សៀក ពិសិដ្ឋ** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកកងមាស

១៤_លោកឧកញ៉ា **ម៉ក់ គឹមហុង** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកកងមាស

១៥_លោកឧកញ៉ា **ម៉ុង ឫទ្ធី** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅវត្តវាំងចាស់

១៦_លោកឧកញ៉ា **ខូវ ជូឈី** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅខេត្តក្រចេះ

១៧_លោកឧញ៉ា **ឡាវ ម៉េងឃីន** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅខេត្តក្រចេះ

១៨_លោក **តូនី តង់ឌីហ្វ្រេឌ** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកគងពិសី

១៩_លោកឧត្តមសេនីយ៍ **ម៉ុខ សំផន** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកស្វាយទាប

២០_លោក **ទ័ថ ប៊ុនស្រ៊ុន** ទឹកប្រាក់ 10.000$US កសាងទំនប់អ្នកលឿង

២១_ឯកឧត្តម **តេខ ឡេទ្បី** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកព្រៃឈរ

២២_ឯកឧត្តម **ខួន ផនស៊ីផុន** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកបាធាយ

២៣_ឯកឧត្តម **អ៊ុ គីមហ៊ាខ** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកកងមាស

២៤_ឯកឧត្តម **លី ផល្លា** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកជើងព្រៃ

២៥_លោកស្រី **សោម សុផល** ទឹកប្រាក់ 17.000$US កសាងវត្តវាំងចាស់

២៦_ឯកឧត្តម **ឡៅ ឆាញ់** ទឹកប្រាក់ 40.000$US កសាងសាលារៀន ២ខ្នង នៅស្រុកក្រឡាញ់

២៧_ឯកឧត្តម **ឈា សុខ** ទឹកប្រាក់ 10.000$US ជួយជួសជុលផ្លូវ នៅខេត្តស្វាយរៀង

២៨_ឯកឧត្តម **ចម ប្រសិទ្ធិ** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅខេត្តសៀមរាប

២៩_ឯកឧត្តម **ឯម សំអាន** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅស្រុកខ្សាច់កណ្តាល

៣០_ឯកឧត្តម **ម៉ុល សារឿន** ទឹកប្រាក់ 30.000$US កសាងផ្លូវលំ នៅស្រុកបរសេដ្ឋ

៣១_ឯកឧត្តម **មាស សុភា** ទឹកប្រាក់ 20.000$US ក [illegible] រៀន ១ខ្នង នៅខេត្តបន្ទាយមានជ័យ

៣២_ឯកឧត្តម **លឹម គានហោ** ទឹកប្រាក់ 10.000$US ចូលរួ [illegible] នៅស្រុកស្អាង

៣៣_ឯកឧត្តម **មល់ រឿប** ទឹកប្រាក់ 20.000$US កសាងសាលារៀន ១ខ្នង នៅខេត្តបាត់ដំបង

៣៤_លោកជំទាវ **ហូ ឈួន** ទឹកប្រាក់ 15.000$US កសាងព្រះវិហារវត្តវាំងចាស់

៣៥_ឯកឧត្តម **យូ ស៊ុនឡុង** ទឹកប្រាក់ 20.000$US កសាងសាលារៀន ស្រុកកងមាស ខេត្តកំពង់ចាម

៣៦_លោកជំទាវ **ទីបូ រ៉ាស៊ី** ទឹកប្រាក់ 15.000$US កសាងព្រះវិហារវត្តវាំងចាស់

៣៧_ឧត្តមសេនីយ៍ **អ៊ិច សំខាន់** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៣៨_ឧត្តមសេនីយ៍ **ឈុំ សុជាតិ** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៣៩_ឧត្តមសេនីយ៍ **ចៅ តិរុណា** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៤០_ឧត្តមសេនីយ៍ **ស៊ុំ សំណាង** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៤១_ឧត្តមសេនីយ៍ **ម៉ក់ សារុន** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៤២_ឧត្តមសេនីយ៍ **ខ្វាន់ ស៊ាម** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៤៣_ឧត្តមសេនីយ៍ **ស៊ឹង សំណាង** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៤៤_វរសេនីយ៍ឯក **អ៊ុំ សុវណ្ណ** ទឹកប្រាក់ 20.000$US សំរាប់កសាងសាលារៀន

៤៥_វរសេនីយ៍ឯក **ជុំ ឃាត់** ទឹកប្រាក់ 10.000$US សំរាប់កសាងសាលារៀន

៤៦_លោកឧកញ៉ា **ឡៅ ឌី** ទឹកប្រាក់ 40.000$US សំរាប់កសាងសាលារៀន ២ខ្នង នៅខេត្តបន្ទាយមានជ័យ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងនាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីទី២ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

III- ការងារបណ្ណាក្រសួង

១_ ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៦៨៦ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អ៊ុន លាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៧៥៩៦ ព.វ ចុះថ្ងៃទី២២-៥-៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិផ្អូម ឃុំព្រៃខ្លាយ «ក» ស្រុកពាមរក៍ ខេត្តព្រៃវែង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង២៤សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **អ៊ុន លាង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអប្បរមាលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៨៧ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **គ្រឹង វេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៤៤១៩ ភ.ព. ចុះថ្ងៃទី២១-៦-៩៧ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩០អឺម្ភ ផ្លូវ ៦១១ សង្កាត់ផ្សារដេប៉ូ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម ផលិតជីស យីហោ «វេង ហេង» នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **គ្រឹង ទេង** ត្រូវអនុញ្ញាតអោយផលិតនូវមុខផលិតផល ជីស យីហោ «វេង ហេង» សញ្ញា «រូបជីរ» ស្របតាមគំរូសញ្ញាសំគាល់ដែលបានសំគល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៨៨ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **គឹម ទី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១១៨៣១៩ ភ.ព. ចុះថ្ងៃទី២៧-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦៨២អា ផ្លូវជាតិលេខ៥ ក្រុមទី១ ភូមិឬស្សីត្បូង សង្កាត់ទួលសង្កែ ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ បន្តដំណើការ រោងជាងក្រឡឹងដែក នៅក្នុងទីតាំងដូចអាស័យ ដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៨៩ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឌី ចន្ទរង្សី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០២៦០២ ចុះថ្ងៃទី១៤-០១-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៨៩ ផ្លូវឧកញ៉ាស៊ូ សង្កាត់ទឹកល្អក់២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

បើកដំណើរការ ឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធសញ្ញា «អប្សារា APSARA » នៅក្នុងទីតាំងដីឡូត៍ថ្មី ផ្លូវជាតិលេខ៦អា ក្រុម០៨ ភូមិកៀនឃ្លាំង សង្កាត់ព្រែកលាប ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ឌី ឧត្តរនោគ** ត្រូវអនុញ្ញាតអោយផលិតនូវមុខផលិតផល ទឹកបរិសុទ្ធសញ្ញា «អប្សារា APSARA » ស្របតាមគំរូសញ្ញាសំគាល់ដែលបានដំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ អង្គអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៩០ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ថាវន់ ម៉ែម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០៨៩៧៩៦ ភ.ព. ចុះថ្ងៃទី១៨-០៣-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៦ ផ្លូវ ១១៣ ក្រុមទី៨ សង្កាត់បឹងព្រលឹត ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បើកដំណើរការ សិប្បកម្មកាត់ដេរកាតាប នៅក្នុងទីតាំងដូចក្នុងអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៩១ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ចាន់ ម៉ិនថន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១៦០០០៤ភ.ព. ចុះថ្ងៃទី០៧-១០-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៤៦អឺអ្វ ផ្លូវ១៨២ សង្កាត់បឹងព្រលឹត ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរ ការ សិប្បកម្មផលិតនំផ្អែម នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ។

ប្រការ ២ : លោក **ចាន់ ម៉ិនថន** ត្រូវបានអនុញ្ញាតិអោយផលិតនូវមុខផលិផលនំផ្អែម សញ្ញា «អប្សរា» ស្របតាមគំរូផ្លាកសញ្ញាដែលបានតំកល់នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយ គ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៩២ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឈឹម ចាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤០៣៧៨ ភ.ព. ចុះថ្ងៃទី២៤-០១-៨៩ អាស័យដ្ឋាន បច្ចុប្បន្ន ផ្ទះលេខ ១៦៨ ផ្លូវ ២១៥ ក្រុមទី២០ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការរោងជាងផលិតទ្វារ-បង្អួចពីអាលុយមីញ៉ូម នៅក្នុងទីតាំង ដូចក្នុងអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៩៣ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ចាន់ ការុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩១៦១៩ ភ.ព. ចុះថ្ងៃទី២៥-៣-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦៦អឺអូ ផ្លូវ២១៧ សង្កាត់អូឬស្សី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការរោងជាងជួសជុលគ្រឿងអគ្គិសនី នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ៦៩៩ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឡុយ ម៉ិនរឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៩៨២៨ ប.ប ចុះថ្ងៃទី២៤-៣-៨៦ អាស័យដ្ឋាន បច្ចុប្បន្ន ក្រុមទី១៤ ភូមិវត្តលៀប ឃុំចំការសំរោង ស្រុកស្វាយចេ៉ា ខេត្តបាត់ដំបង បន្តដំណើរការ សិប្បកម្មថ្មត្បូង នៅក្នុងទីតាំង ក្រុមទី១៤ ភូមិវត្តលៀប ឃុំចំការសំរោង ស្រុកស្វាយចេ៉ា ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០០ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ តាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៦០៧៤ ប.ប ចុះថ្ងៃទី១០-៦-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៣១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការ សិប្បកម្មថ្មត្បូង នៅក្នុងទីតាំងក្រុមទី៣១ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០១ ឧក.ប្រក. ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **សុត សុជា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០០៨៧០១ ភ.ព. ចុះថ្ងៃទី៩-១២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៦ ភូមិអូរតាគាំ២ ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការ ថ្មត្បូង នៅក្នុងទីតាំង ក្រុមទី៦ ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៧០២ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឡោក់ ស៊ាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណបណ្ណលេខ ០២០៥៤២ ប.ជ ចុះថ្ងៃទី២០-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៨ ក្រុមទី២ ភូមិអូរស្លុត ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង៧៧សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឡោក់ ស៊ាន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចមានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០៣ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ហ៊ុន សំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណបណ្ណលេខ ០០៣០៣៧ ប.ជ ចុះថ្ងៃទី២៩-១១-៩១ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៧ ភូមិបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ហ៊ុន សំ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចមានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០៤ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ទៀន គូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៤៦៦១ ប.ជ ចុះថ្ងៃទី១៤-១១-៨៩ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣២៨ ភូមិ៤ ឃុំព្រះពន្លា ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៦៩សេះ នៅក្នុងទីតាំង ដូចអាសយដ្ឋានខាងលើ ។

ប្រការ ២ : លោក **ទៀន គូ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចមានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដក ហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០៥ ផក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ម៉ៅ ប្លួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០៩៨៦៨៥ ប.ជ ចុះថ្ងៃទី២២-៦-៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរអំពិល ឃុំអូរអំពិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៣៥សេះ នៅក្នុងទីតាំងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : លោក **ម៉ៅ ប្លួយ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចមានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០៦ ផក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **តាន់ ទ៉ា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០២៣៦៦ប.ជ ចុះថ្ងៃទី០៤-៥-៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៥៩៥ ក្រុមទី៣៦ ភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៥១ សេះ នៅក្នុងទីតាំងក្រុមទី ៨ ភូមិគោកទន្ទាប់ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ លោក **តាន់ ទ័រ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចមានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០៧ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ហោ ឌីន** ជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០សេះ ដែលមានទីតាំង ភូមិសំរោង ក្នុងឃុំសំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់គ្រងលើរោងម៉ាស៊ីនកិនស្រូវជូនលោក **មាស សេខ** វិញ ។

ប្រការ ២ : លោក **មាស សេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២២៨៦០ ប.ប. ចុះថ្ងៃទី ២៧-៨-៩០ អាស្រ័យដ្ឋានបច្ចុប្បន្ន ភូមិអញ្ចាញ ឃុំអូរចារ ស្រុកស្វាយចៀ ខេត្តបាត់ដំបង ។ ជាម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំងដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០៨ ឧក.ប្រក. ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូច ផលិតទឹកកកដើម ដែលមានអ្នកស្រី **ហ៊ួត ស៊ាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៧៦០២០ ព.រ ចុះថ្ងៃទី២៣-១១-៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ៤ ឃុំព្រែកខ្សាយ «ខ» ស្រុកពាមរក៍ ខេត្តព្រៃវែង បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំង ភូមិ ៤ ឃុំព្រែកខ្សាយ«ខ» ស្រុកពាមរក៍ ខេត្តព្រៃវែង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មាន សំណងឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ពូ សុធីរៈ

* * *

២_ ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

ស្តីពីការតែងតាំងមន្ត្រីរាជការ

ប្រកាសលេខ ២០២ ពម.ប្រក.

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស / រកត / ០១៩៦ / ១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញសំណើ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧ របស់អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ
- យោងតាមការចាំបាច់
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១. តែងតាំងលោក ទេព យ៉ាត ជាអនុប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងពត៌មាន ។

ប្រការ ២. ឯកឧត្តមអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ, លោកនាយកខុទ្ទកាល័យ, បណ្តាអគ្គនាយកដ្ឋានចំណុះ, លោកប្រធាននាយកដ្ឋានរដ្ឋបាល, លោកប្រធាននាយកដ្ឋានបុគ្គលិក, លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ-ហិរញ្ញវត្ថុ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

ប្រកាសលេខ ២០៣ ពម.ប្រក.

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម លេខ ០១៩៦/១៤ នស/រកម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- យោងតាមសំណើលេខ ០០៩/៩៧/សពខ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ របស់ទីភ្នាក់ងារសារពត៌ខ្មែរ "AKP" ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **រាល ម៉ារ៉ាទី** ជាអនុប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានខ្មែរ AKP «ក្រសួងពត៌មាន» ។

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ, លោកនាយកខុទ្ទកាល័យ, លោកអគ្គនាយកទីភ្នាក់ងារសារពត៌មានខ្មែរ AKP លោកប្រធាននាយកដ្ឋាន បុគ្គលិក, លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ-ហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

ប្រកាសលេខ ២០៤ ពម.ប្រក.
ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ០១៩៦/១៤ នស/រកម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- យោងតាមសំណើលេខ ០១០/៩៧/សួពខ. ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ របស់ទីភ្នាក់ងារសារពត៌មានខ្មែរ "AKP" ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **តិន ដាវាឌុឌ** ជាអនុប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋាន ទីភ្នាក់ ងារសារពត៌មានខ្មែរ AKP «ក្រសួងពត៌មាន» ។

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ, លោកនាយកខុទ្ទកាល័យ, លោកអគ្គនាយកទីភ្នាក់ងារសារពត៌មានខ្មែរ AKP លោកប្រធាននាយកដ្ឋានបុគ្គលិក, លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ-ហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧

ប្រកាសលេខ ២០៥ ពម.ប្រក.

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្យទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់មន្ត្រីរាជការ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពត៌មាន

សំរេច

ប្រការ ១ : តែងតាំង មន្ត្រីរាជការចំនួន ០២ នាក់ ជាថ្នាក់ការិយាល័យនៅអគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ «អា.កា.ប៉េ» នៃក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោមនេះ:

១- លោក **ម៉ាន់ ហេង** ជាប្រធានការិយាល័យគណនេយ្យ

២- លោក **អ៊ុក សុឌ្ឍរី** ជាប្រធានការិយាល័យបុគ្គលិក

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ, លោកនាយកខុទ្ទកាល័យ, លោកអគ្គនាយកទីភ្នាក់ងារសារពត៌មានខ្មែរ AKP បណ្តាអគ្គនាយកដ្ឋានចំណុះក្រសួង, លោកប្រធាននាយកដ្ឋានបុគ្គលិក, លោកប្រធាននាយកដ្ឋានផែនការគណនេយ្យហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវអនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

៣_ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧

សេចក្តីសំរេចលេខ ៤២៥ សសរ.មស.ក្រខ.
ស្តីពីការបែងចែកនិស្សិតចំនួន ២២ នាក់
ដែលទើបបញ្ចប់ការសិក្សាពីបរទេស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំនួន ២ នាក់ ថ្នាក់ឧត្តមចំនួន ២០ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំពេញការងារនៅក្រសួង ស្ថាប័ន មួយចំនួនដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ត្រូវ
រៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជន ចាប់
ពីថ្ងៃដែលបានចូលបំពេញការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

តារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ៥០៥ សសរមស.ក្រខ. ចុះថ្ងៃទី៣០-៧-៩៧
ស្តីពីការបែងចែកនិស្សិតចំនួន ២២នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស

នាមត្រកូល នាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អត្តភាពដើម	មុខជំនាញបច្ចេកទេស	កំរិតបណ្ឌុះបណ្ដាល	បៀវត្ស	ប្រភពបណ្ឌុះបណ្ដាល
១_ ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០១ នាក់							
ផា វ៉ាន់ដេត	ប	០២-៤-៧៣	សិស្ស	សេដ្ឋកិច្ច	បណ្ឌិត វ៉	៩០% ខ I ៤	២
២_ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ចំនួន ០១ នាក់							
អ៊ុង វិទ្ធី	ប	០៦-០១-៧០	សិស្ស	គតិមាត្រវិទ្យា	ឧត្តម	៩០% ខ I ១	១
៣_ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ០២ នាក់							
នូវ សុខសម្បត្តិ	ប	២០-៤-៦២	សិស្ស	សេដ្ឋកិច្ច	បណ្ឌិត វ៉	៩០% ខ I ៤	២
មៀវ ឯកសុវណ្ណារ	ប	០១-៧-៧៣	សិស្ស	គតិមាត្រវិទ្យា	ឧត្តម	៩០% ខ I ១	១
៤_ ក្រសួងយុត្តិធម៌ចំនួន ០២នាក់							
	ប	០៥-៤-៦៩	ប៉ុ យុត្តិធម៌	ច្បាប់អន្តរជាតិ	ឧត្តម	ខ I ១	១
	ប	២០-០១-៦៦	ប៉ុ យុត្តិធម៌	ច្បាប់អន្តរជាតិ	ឧត្តម	ខ I ១	១
៥_ ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ០៤នាក់							
	ប	០១-១០-៧៣	សិស្ស	អេឡិចត្រូនិច និងទូរគមនាគមន៍	ឧត្តម	៩០% ខ I ១	១
	ប	១៧-៤-៧១	សិស្ស	អេឡិចត្រូនិច និងទូរគមនាគមន៍	ឧត្តម	៩០% ខ I ១	១
...ត	ប	០៧-៥-៧៤	សិស្ស	គតិមាត្រវិទ្យា	ឧត្តម	៩០% ខ I ១	១

១០	ខាន់ សុភា	ប	១៧-៨-៧២	សិស្ស	អេឡិចត្រូនិច និងទូរគមនាគមន៍	ឧត្តម	៩០% ខ ១	២

៦_ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំនួន ៥ នាក់

១១	ល្បៀង គុណ	ប	១៦-១២-៧៣	សិស្ស	រុក្ខកម្ម	ឧត្តម	៩០% ខ ១	១
១២	ហុង សុជាតិ	ប	០៧-០១-៧០	សិស្ស	រុក្ខកម្ម	ឧត្តម	៩០% ខ ១	១
១៣	ឌួន សុខុម	ប	២៦-០១-៧១	បុ ខណ្ឌ ដូនពេញ	រុក្ខកម្ម	ឧត្តម	ខ ១	១
១៤	ប៉ែន សំផាន	ប	១៣-០២-៦៣	បុ កសិកម្ម	កែច្នៃផលិតផលឈើ	ឧត្តម	ខ ១	៣
១៥	ជិ គីមអ៊ី	ប	០១-១០-៦៧	សិស្ស	គតិមានវិទ្យា	ឧត្តម	៩០%ខ ១	១

៧_ ក្រសួងអប់រំ យុវជន និង កីឡា ចំនួន ០១នាក់

១៦	ឆាយ ផាង	ប	២២-១១-៧២	សិស្ស	គតិមានវិទ្យា	ឧត្តម	៩០%ខ ១	១

៨_ ក្រសួង មហាផ្ទៃ ចំនួន ០១នាក់

១៧	មៀង តាយ	ប	០៣-៥-៧៣	សិស្ស	គតិមានវិទ្យា	ឧត្តម	៩០%ខ ១	១

៩_ ក្រសួង សាធារណការ និង ដឹកជញ្ជូន ចំនួន ០២នាក់

១៨	គង់ ណៃហួត	ប	០៨-៨-៧២	សិស្ស	បើកបរនាវាសមុទ្រ	ឧត្តម	៩០%ខ ១	១
១៩	ម៉ាន់ យឿន	ប	១៥-៧-៧៣	សិស្ស	បើកបរនាវាសមុទ្រ	ឧត្តម	៩០%ខ ១	១

១០_ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចំនួន ០១នាក់

២០	អ៊ូច រតនា	ប	០៥-០១-៧០	សិស្ស	ចំរាញ់ប្រេងកាត	ឧត្តម	៩០%ខ ១	១

១១_ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចំនួន ០២រូប

២១	សុក ផុនដានី	ប	០៥-១០-៦៨	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	៩០%ខ ១	១

២២	សរ ច័ន្ទតារា	ប	០៥-០១-៦៩	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	៩០%ខ	១	១

បានបញ្ឈប់បញ្ជីនេះត្រឹមចំនួន ២២នាក់ ប៉ុណ្ណោះ

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៧

សេចក្តីបញ្ជាក់ :

១_ប្រទេសវៀតណាម

២_ប្រទេសសូវៀត

៣_ប្រទេសអាល្លឺម៉ង់

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

* * *

៤_ ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៧

សេចក្តីសំរេចលេខ ១៨៦ ក.ធ.ស.

* * *

ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម. ០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦/នស/១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២/អនក្រ. ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា

- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះនៃសាសនា ព្រះនាងគង់ស៊ីអ៊ីម «ចិន» របស់លោក លី សៀសីង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តកំពតលេខ ៩៩/លចបកព. ៩៧. ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះនៃសាសនា ព្រះនាងគង់ស៊ីអ៊ីម «ចិន» មានឈ្មោះហៅថា « **ខុង មីងតាតាង** » មួយកន្លែងមានទីតាំងស្ថិតនៅ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះ នៃព្រះវិហារ « **ខុង មីងតាតាង** » ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយ នូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនា ព្រះនាងគង់ស៊ីអ៊ីម ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារ «**ខុង មីងតាតាង**» ត្រូវគោរពនិងអនុវត្ត អោយបានត្រឹមត្រូវតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្សាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការ អនុវត្តទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាណ ។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការ និងសាសនាខេត្តកំពត និងមន្ទីររាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍ សេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា ចិច ប្វា

ហៀន វណ្ណេរិទ្ធ

* * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី

លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល